ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ ៧.០២.២២០ ប្រ.ក

# ប្រកាស
## ស្តីពី
## ប្រតិបត្តិការលើមូលបត្ររបស់ធនាគារ
## ដែលមានអាជ្ញាប័ណ្ណ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

~~~~~~~~~~

### ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃ ធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៣៩ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាជាថ្មីម្តងទៀត
- តាមសំណើរបស់អគ្គនាយកដ្ឋាន
- យោងតាមការឯកភាពរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០០២

### ស ម្រេ ច

**ប្រការ ១:**

ធនាគារជាតិនៃកម្ពុជាគាំទ្រនិងបង្កលក្ខណៈអំណោយផលដល់ការរីកលូតលាស់និងកិច្ចអភិវឌ្ឍន៍នៃទីផ្សារមូលប័ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលការណ៍សុវត្ថិភាព ភាពរឹងមាំ និងប្រសិទ្ធភាពនៃប្រព័ន្ធហិរញ្ញវត្ថុ ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជានឹងសំរបសំរួលនីតិវិធីគណនេយ្យ និងប្រតិបត្តិការរបស់ខ្លួនក្នុងគោលបំណងសំរួលការផ្តល់ឥណទាន និងការជួញដូរមូលប័ត្រជាអន្តរធនាគារ ។ លើសពីនេះទៀត ធនាគារជាតិនៃ
~~~~~~~~~~

កម្ពុជានឹងអនុវត្តនូវស្តង់ដារពិសេសសំរាប់ប្រើការត្រួតពិនិត្យធនាគារទាំងឡាយដែលដើរតួជាជើងសារការី ឬជាប្រតិបត្តិករមូលប័ត្រ ។

## ប្រការ ២៖

ធនាគារត្រូវបានចាត់ទុកថាជាប្រតិបត្តិករជើងសារការីឬជាប្រតិបត្តិករមូលប័ត្រ បើធនាគារនោះផ្តល់ការធានា ឬជួញដូរ ឬធ្វើប្រព្រឹត្តិកម្មមូលប័ត្រ ។ ប្រសិនបើការទិញនិងលក់មូលប័ត្ររយៈពេលខ្លី តាមរូបភាពដែលបង្ហាញឱ្យប្រតិបត្តិករមូលប័ត្រឬវិនិយោគិនដទៃទៀតយល់ឃើញថា ធនាគារធ្វើប្រតិបត្តិការលើមូលប័ត្រ ធនាគារនោះត្រូវបានចាត់ទុកថាធ្វើសកម្មភាពជួញដូរមូលប័ត្រ ដោយពុំគិតដល់ផ្នែកណាមួយនៃធនាគារជាអ្នកចាត់ចែងដំណើរប្រតិបត្តិការទាំងនោះឡើយ ។

## ប្រការ ៣៖

ការសំរបសំរួលនីតិវិធីប្រតិបត្តិការនិងគណនេយ្យរបស់ធនាគារជាតិនៃកម្ពុជា រួមមានការអនុញ្ញាតឱ្យធនាគារ ផ្ទេរមូលនិធិពីគណនីចរន្តរបស់ខ្លួនទៅកាន់គណនីចរន្តរបស់ធនាគារដទៃនៅធនាគារជាតិនៃកម្ពុជា តាមវិធីប្រើបញ្ជាទូទាត់តាមទូរស័ព្ទជាលើកដំបូងទៅធនាគារជាតិនៃកម្ពុជា ដោយមានការសួរបញ្ជាក់តបវិញ ។ ដើម្បីអនុវត្តវិធីនេះ ធនាគារបញ្ជាផ្ទេរប្រាក់ និងធនាគារទទួលប្រាក់ ចាំបាច់ត្រូវធ្វើកិច្ចព្រមព្រៀងគោល ដែលត្រូវផ្ញើជូនមកធនាគារជាតិនៃកម្ពុជាជាមុន ។ កិច្ចព្រមព្រៀងនេះត្រូវចែងអំពីប្រការទាំងឡាយបង្ហាញពីការស្រុះស្រួលគ្នាធ្វើប្រតិបត្តិការបែបនេះ និងមានការអនុញ្ញាតពីក្រុមប្រឹក្សាភិបាលរបស់សាមីធនាគារទៀងខ្លួនផងដែរ ។

លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជានឹងបង្កើតប្រព័ន្ធចុះបញ្ជីសំរាប់មូលប័ត្ររបស់រដ្ឋាភិបាលនៅពេលណាដែលមូលប័ត្រនេះត្រូវបានចេញផ្សាយ ។ កិច្ចព្រមព្រៀងផ្ទេរតាមទូរស័ព្ទដូចគ្នាខាងលើសំរាប់ការជួញដូរមូលប័ត្ររបស់រដ្ឋាភិបាលក្នុងចំណោមធនាគារ នឹងត្រូវបង្កើតឡើងនៅពេលនោះ ។

## ប្រការ ៤៖

ធនាគារជាតិនៃកម្ពុជានឹងធ្វើការត្រួតពិនិត្យលើសកម្មភាពរបស់ធនាគារ ដែលធ្វើសកម្មភាពជួញដូរមូលប័ត្រ ។ នីតិវិធីនៃការត្រួតពិនិត្យរួមមានការត្រួតពិនិត្យមើលក្រុមប្រឹក្សាភិបាលនិងការគ្រប់គ្រង ការត្រួតពិនិត្យលើគោលនយោបាយនិងការគ្រប់គ្រងហានិភ័យ ការថែរក្សាឯកសារកត់ត្រានិងភាពត្រឹមត្រូវនៃប្រតិបត្តិការ ការអនុវត្តការជួញដូរនិងការបែងចែកភារកិច្ច ការងារបណ្តុះបណ្តាលនិងកម្មវិធីផ្តល់កំរៃដល់ប្រតិបត្តិករនិងបុគ្គលិក ការកាន់កាប់មូលប័ត្រនិងការកត់ត្រាការជួញដូរ និងទិដ្ឋភាពដទៃទៀតនៃប្រតិបត្តិការទាំងឡាយដែលពាក់ព័ន្ធ ។ ការត្រួតពិនិត្យបែបនេះអាចជាផ្នែកមួយនៃការត្រួតពិនិត្យ ជាទូទៅលើធនាគារ ឬអាចមានលក្ខណៈដោយឡែកពីការត្រួតពិនិត្យដទៃទៀត ។

**ប្រការ ៥:**

រាល់របាយការណ៍ត្រួតពិនិត្យទាំងអស់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា គឺជាកម្មសិទ្ធិផ្តាច់មុខរបស់ធនាគារជាតិនៃកម្ពុជា ហើយមិនអាចថតចំលង ឬបញ្ជូនដោយគ្មានការឯកភាពពីធនាគារជាតិនៃកម្ពុជាឡើយលើកលែងតែក្នុងករណីដែលច្បាប់អនុញ្ញាត ។

**ប្រការ ៦:**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧:**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានរបស់ធនាគារជាតិនៃកម្ពុជា និង គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលនៃធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៨:**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/

រាជធានីភ្នំពេញ, ថ្ងៃទី២៥ខែ ធ្នូ ឆ្នាំ ២០០២

**អភិបាល**

**ជា_ចាន់តូ**

**កន្លែងទទួល**

- ដូចប្រការ ៧ ដើម្បីអនុវត្ត
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"